# លក្ខន្តិកៈ
# ពុទ្ធិកសមាគមកម្ពុជរដ្ឋ

## ជំពូកទី១
## ការបង្កើត

**ប្រការ ១-** ជនទាំងឡាយជាគ្រហស្ថ ឬបព្វជិត ដែលគាប់ចិត្តនឹងលក្ខន្តិកៈនេះ បានរួបរួមគ្នាបង្កើតសមាគមមួយ មានឈ្មោះថា **ពុទ្ធិកសមាគមកម្ពុជរដ្ឋ** ប្រើអក្សរកាត់ថា **ព.ស.ក** ។

-ព.ស.ក ជាសមាគម មិនរកកម្រៃ ។

-ព.ស.ក ជាសមាគមមិនបម្រើនិន្នាការនយោបាយគណបក្ស។

-ព.ស.ក ប្រើទង់មានពណ៌ ៦ តម្រូវតាមឆព្វណ្ណរង្សីរបស់ព្រះពុទ្ធ ដែលពុទ្ធិកសមាគមពិភពលោក (ព.ស.ព) បានបង្កើតនៅក្នុងសម័យប្រជុំពេញអង្គលើកទី១ ឆ្នាំ ១៩៥០ នៅក្រុងកូឡុំបូ ប្រទេសស្រីលង្កា ។

-ត្រារបស់ ព.ស.ក ជារូបធម្មចក្ក មានកាំ៨ តាងអរិយមគ្គមានអង្គ ៨ ។

-ព.ស.ក មានទីស្នាក់ការ នៅទីក្រុងភ្នំពេញ។

## គោលបំណង និង កម្មវត្ថុ

**ប្រការ ២-** ព.ស.ក មានគោលបំណង និងកម្មវត្ថុទាំងឡាយ ដូចតទៅនេះ គឺ:

ក/ ឧបត្ថម្ភ ណែនាំ សមាជិក ឱ្យយកចិត្តទុកដាក់ស្វែងយល់ ពុទ្ធសាសនា ដើម្បីប្រតិបត្តិត្រឹមត្រូវតាមពុទ្ធោវាទ

ខ/ ប្រើគ្រប់មធ្យោបាយ ដើម្បីរួមចំណែកធ្វើឱ្យមានការឯកភាពសាមគ្គីភាព និងភាតរភាព រវាងពុទ្ធមាមកជនខ្មែរទាំងក្នុង និងក្រៅប្រទេស ព្រមទាំងពុទ្ធមាមកជនបរទេសផងដែរ ជាពិសេស រួមចំណែកពង្រឹងការអនុវត្តន៍សង្ឃប្រកាស សេចក្តីសម្រេច សារាចរ របស់ក្រសួងព្រះសង្ឃរាជ និង ក្រសួងធម្មការ និងសាសនា ដោយខិតខំជួយជម្រុញកិច្ចការសាសនា ឱ្យបានល្អមានសមត្ថភាព ចាត់ចែងការងារ គ្រប់គ្រងវត្តអារាមមានរបៀបរៀបរយល្អ បម្រើសំណូមពរពុទ្ធបរិស័ទ ខាងស្មារតី និងសីលធម៌ ធ្វើឱ្យវត្តអារាមនីមួយៗ ប្រែក្លាយជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន។

គ/ ផ្សព្វផ្សាយព្រហ្មចរិយធម៌ និងឱវាទផ្សេងៗ របស់ព្រះសម្ពុទ្ធ។

ឃ/ ចាត់ចែងធ្វើសកម្មភាពប្រជាសង្គ្រោះ ការសិក្សាអប់រំសីលធម៌សង្គម និងវប្បធម៌សន្តិភាព តាមគន្លងព្រះពុទ្ធសាសនា និងកិច្ចការមនុស្សធម៌ដទៃទៀត ចំពោះសមាជិក និងពុទ្ធសាសនិក ព្រមទាំងសាធារណជនទូទៅ។

ង/ ប្រើគ្រប់មធ្យោបាយ ដើម្បីរួមចំណែកធ្វើឱ្យមានសន្តិភាព សុភមង្គល និងសុខុដុមរមនា រវាងមនុស្សជាតិ

រួមជាមួយអង្គការដទៃទៀតដែលមានគោលបំណងដូចគ្នា ។

ច/ រួមចំណែកបណ្តុះបណ្តាលធនធានបញ្ញា ក្នុងជួរបព្វជិត ដោយឧបត្ថម្ភសមណនិស្សិត ឬសមាជិក ដែលត្រូវទៅបំពេញវិជ្ជាពុទ្ធសាសនាឯក្រៅប្រទេស និងពុទ្ធិកសិក្សាក្នុងប្រទេស ស្របតាមល័ក្ខខ័ណ្ឌ ដែលគណៈកម្មាធិការនាយក និងកំណត់នៅពេលក្រោយ ។

## ជំពូក ២

## ក. ការឧបត្ថម្ភ

**ប្រការ ៣:** ព.ស.ក នៅក្រោមព្រះបរមរាជូបត្ថម្ភ និង ព្រះបរមរាជធិបតីភាពនៃព្រះមហាក្សត្រ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## ខ. សមាជិកភាព

**ប្រការ ៤:** ព.ស.ក មានសមាជិក ៤ ប្រភេទ ទាំងជារូបវន្តបុគ្គល និងទាំងជានីតិបុគ្គល ដូចតទៅនេះ :

-សមាជិកកិត្តិយស

-ជនកសមាជិក

-កម្មិកសមាជិក

-បាសាទិកសមាជិក។

ក/ សមាជិកកិត្តិយស : ត្រូវទុកប្រគេន -ថ្វាយ -ជូន ឥស្សរជនជាន់ខ្ពស់ ដូចតទៅ :

-សម្តេចសង្ឃរាជទាំងពីរគណៈ

-ប្រធានសភាទាំងពីរ

-នាយករដ្ឋមន្ត្រី

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

-ប្រធានតុលាការកំពូល ។

ប្រធានកិត្តិយស សមាជិកកិត្តិយស និង ទីប្រឹក្សា នៃព.ស.ក មានសិទ្ធិផ្តល់មតិណែនាំដល់ ព.ស.ក គ្រប់កាលៈទេសៈ។

ខ/ ជនកសមាជិក : គឺជាសមាជិស្ថាបនិក ដែលបានរួបរួមកម្លាំងកាយ ចិត្ត និងសម្ភារៈបង្កបង្កើត ព.ស.ក ហើយបានបង់ប្រាក់ជូន សមាគមដំបូងយ៉ាងតិច ព.ស.ក ២០.០០០៛០០ (ពីរម៉ឺនរៀលគត់) ព្រមទាំងបានបង់ប្រាក់ភាគទានប្រចាំខែ ដូចមានកម្រិតក្នុងប្រការ ៥ ។

គ/ កម្មិកសមាជិក : គឺជាសមាជិកដែលរួមចំណែកបង់ប្រាក់ភាគទានរៀងរាល់ខែ ដូចមានកម្រិតក្នុងប្រការ៥ ទាំងសមាជិកសកម្មមានឆន្ទៈល្អ ជួយទាំងកម្លាំងកាយ-ចិត្ត និងថវិកាជានិច្ចកាលដើម្បីឱ្យសមាគមរីកចម្រើន ចំពោះ ទីណាពេលណាឡើយ ។

ឃ/ បាសាទិកសមាជិក : គឺជាសមាជិកដែលមានចិត្តសោមនស្សចំពោះគោលបំណង និងកម្មវិធីសកម្មភាព របស់ ព.ស.ក អាចជួយសមាគមតាមសេចក្ដីជ្រះថ្លារបស់ខ្លួន ទាំងកម្លាំងកាយ-ចិត្ត ព្រមទាំងថវិកា និង ទេយ្យវត្ថុផ្សេងៗ មិនកំណត់ចំនួន តាមលទ្ធភាព និងពេលវេលា ។

**ប្រការ ៥**- ជនកសមាជិក កម្មិកសមាជិក ត្រូវបង់ប្រាក់ភាគទាន មានចំនួនស្មើគ្នាជូន ព.ស.ក រៀងរាល់ខែ ក្នុងមួយខែ ១.០០០៛០០ (មួយពាន់រៀលគត់) ។ សមាជិកទាំងពីរប្រភេទនេះ អាចបង់ប្រាក់ភាគទាន របស់ខ្លួនទុកជាមុន សម្រាប់ត្រីមាស ៣.០០០៛០០ (បីពាន់រៀល) ឆមាស ៦.០០០៛០០ (ប្រាំមួយពាន់រៀលគត់) ឬប្រចាំឆ្នាំ ១២.០០០៛០០ (មួយម៉ឺនពីរពាន់រៀល) ក៏បាន ។

**ប្រការ ៦**- ព.ស.ក និងចេញសព្ទិប័ណ្ណឱ្យជនណាមួយ លុះណាតែសមាគមបានទទួលការឧបត្ថម្ភ ឬអំណោយជាថវិកា ឬទេយ្យវត្ថុពីជននោះដែលមានតម្លៃយ៉ាងតិច ២០.០០០៛០០ (ពីរម៉ឺនរៀល) ព្រមទាំងបានចុះនាមជននោះ ជាសមាជិកក្នុងសៀវភៅបញ្ជីហើយ ។

**ប្រការ ៧**- ពាក្យសុំចូលជាសមាជិក ព.ស.ក សម្រាប់បេក្ខជននៅក្រុងភ្នំពេញ ត្រូវជូនទៅប្រធានគណៈកម្មការ ព.ស.ក ក្រុងភ្នំពេញ សម្រាប់បេក្ខជននៅខេត្ត ក្រុង ស្រុក ឃុំ ត្រូវជូនទៅប្រធានគណៈកម្មការ ព.ស.ក ក្នុងតំបន់របស់ខ្លួន ។ គណៈកម្មការ ព.ស.ក ខេត្ត ក្រុង ត្រូវផ្ញើបញ្ជីសរុបសមាជិក ជូនទៅគណៈកម្មាធិការនាយក ព.ស.ក នៅភ្នំពេញ ។

ចំពោះក្រុងភ្នំពេញ ពាក្យសុំចូលចាសមាជិក ព.ស.ក អាចជូនត្រង់ទៅគណៈកម្មការនាយក ព.ស.ក ។

ចំពោះពុទ្ធមាមកជនខ្មែរនៅក្រៅប្រទេស អាចដាក់ពាក្យសុំចូល សមាជិក ព.ស.ក ជូនគណៈកម្មាធិការនាយក ព.ស.ក នៅទីក្រុងភ្នំពេញឬនៅតំបន់របស់ខ្លួន ដែលមានតំណាងចាត់តាំងដោយ គណៈកម្មាធិការនាយក ព.ស.ក ។

**ប្រការ ៨**- សមាជិកភាពផុតរលត់ ដោយការសុំលាលែង ការលុបឈ្មោះចេញពីបញ្ជី ឬការបញ្ឈប់ដោយប្រការណាមួយ ឬក៏ដោយមរណៈភាព ។

**ប្រការ ៩**- សមាជិកណាមួយដែលសុំលាលែង ត្រូវជំរាបទៅការិយាល័យគណៈកម្មការ ព.ស.ក ជាលាយលក្សណ៍អក្សរ ។

សមជិកណាម្នាក់ មិនបានបង់ប្រាក់ភាគទានចំនួន ៦ខែ ត្រូវទុកជាការលាលែងដោយឯងៗ ។

ការបញ្ឈប់សមាជិកណាមួយ ត្រូវសមាជិកភាគច្រើនដោយដាច់ខាតនៃគណៈកម្មាធិការនាយក ព.ស.ក ជាអ្នកសម្រេច បើឃើញជាសមាជិក នោះបានប្រព្រឹត្តទាស់ខុសខ្លាំងចំពោះលក្ខន្តិកៈ ព.ស.ក ។

**លក្ខន្តិកៈពុទ្ធិកសមាគមកម្ពុជរដ្ឋ**

សមាជិកដែលត្រូវបញ្ឈប់ អាចតវ៉ានៅឱកាសមហាសន្និបាតខាងមុខបាន។ មហាសន្និបាតសម្រេចតាមភាគច្រើនដាច់ខាត (៥០% + ១) នៃសមាជិកមកប្រជុំ ។

**ប្រការ ១០**- សមាជិកណាមួយដែលសុំលាលែង ឬត្រូវបញ្ឈប់ មិនអាចទាមទារអត្ថប្រយោជន៍អ្វីមួយពី ព.ស.ក ទាំងមិនអាចទាមទារប្រាក់ភាគទានដែលខ្លួនបានបង់ជូន ព.ស.ក បានឡើយ ទោះបីបង់ជារបៀបណាក៏ដោយ។

## ជំពូក ៣

## ការគ្រប់គ្រង

**ប្រការ ១១**- ព.ស.ក នៅក្រោមការគ្រប់គ្រង របស់គណៈកម្មាធិការនាយកមួយ ដែលមានសមាសភាពដូចតទៅនេះ

| | |
|---|---|
| -ប្រធាន | ១រូប |
| -អនុប្រធាន ទី១ | ១រូប |
| -អនុប្រធាន ទី២ | ១រូប |
| -អគ្គលេខាធិការ | ១រូប |
| -សមាជិក | ៨រូប |
| -ហេរញ្ញិក | ១រូប |
| -លេខាធិការ | ២រូប |
| -គណនេយ្យករ | ១រូប |
| -បេឡាធិការ | ១រូប |

* មហាសន្និបាតអាណត្តិទី២. ២៩.០៥.០៣ បានបន្ថែមសមាជិកបួនរូប រួមជា ១៧ រូប

**ប្រការ ១២**- មហាសន្និបាត ព.ស.ក ជ្រើសតាំងស្នងការគណនេយ្យ ៣ រូប សម្រាប់អាណត្តិ ២ឆ្នាំ ។

**ប្រការ ១៣**- សមាជិកនៃគណៈកម្មាធិការនាយកត្រូវជ្រើសតាំង សម្រាប់អាណត្តិពីរឆ្នាំ តាមរបៀបដែលបានកំណត់ពីប្រការ ៣២ ទៅ ៤១ ។

ប្រសិនបើមានតំណែងណាមួយនៃគណៈកម្មាធិការនាយក ព.ស.ក ទំនេរ នោះគណៈកម្មាធិការនាយកបើយល់ថាគួរ អាចចាត់តាំងសមាជិកម្នាក់ជំនួសបាន ហើយធ្វើការរហូតដល់ពេលរៀបចំគណៈកម្មាធិការនាយក ព.ស.ក ថ្មី ។

ប្រការ ១៤- គណៈកម្មាធិការនាយក ព.ស.ក ធ្វើបទបញ្ជាផ្ទៃក្នុងមួយសម្រាប់ខ្លួន។

**លក្ខន្តិកៈពុទ្ធិកសមាគមកម្ពុជរដ្ឋ**

គណៈកម្មាធិការនាយក អាចជ្រើសតាំងទីប្រឹក្សាមិនកំណត់ចំនួន ដោយមានព្រះសង្ឃទាំងពីរគណៈចូលរួមផង និងអាចជ្រើសតាំងគណៈកម្មាការនានាបាន ទៅតាមការយល់ឃើញរបស់គណៈកម្មាធិការនាយក ដោយមានលិខិតតែងតាំង និងបញ្ជាក់តួនាទី ភារកិច្ចផង ជាអាទិ៍មានៈ

ក/- គណៈកម្មការឃោសនា និងបោះពុម្ពផ្សាយ

ខ/- គណៈកម្មការអប់រំសីលធម៌ និងវប្បធម៌សន្តិភាព

គ/- គណៈកម្មការកិច្ចការមនុស្សធម៌

ឃ/- គណៈកម្មាការទំនាក់ទំនងសាធារណៈ

ង/- គណៈកម្មាការហិរញ្ញវត្ថុ ។

**ប្រការ ១៥**- ប្រធានគណៈកម្មការនីមួយៗ នៃ គណៈកម្មាធិការនាយក ព.ស.ក និងប្រធានគណៈកម្មការ ព.ស.ក និងប្រធានគណៈកម្មការ ព.ស.ក ខេត្ត ក្រុង ជាអ្នកអញ្ជើញសមាជិករបស់ខ្លួនមកប្រជុំ ជាអ្នកធ្វើកំណត់ហេតុនៃអង្គប្រជុំ ទាំងជាអ្នកជូនសេចក្តីកត់ហេតុនេះទៅគណៈកម្មាធិការនាយក ព.ស.ក ដើម្បីពិនិត្យ និងសម្រេច។

**ប្រការ ១៦**- គណៈកម្មាធិការនាយក ត្រូវកំណត់ភារកិច្ចជូនគណៈកម្មការ ព.ស.ក ខេត្ត ក្រុង ដូចមានចែងក្នុងប្រការ ២១-៣០។

ជាបណ្តោះអាសន្ន គណៈកម្មាធិការនាយកនៃ ព.ស.ក ជាអ្នកតែងតាំងគណៈកម្មការ ព.ស.ក ខេត្ត ក្រុង តាមសេចក្តីស្នើសុំរបស់ព្រះមេគណ និង ប្រធានមន្ទីរធម្មការខេត្ត ក្រុង ។ អាណត្តិរបស់គណៈកម្មការ ព.ស.ក ខេត្ត ក្រុង មានរយៈពេលពីរឆ្នាំ ។

**ប្រការ ១៧**- ប្រសិនបើមានទំណែងណាមួយ នៃគណៈកម្មការ ព.ស.ក ខេត្ត ក្រុង ទំនេរ គណៈកម្មការនេះត្រូវជូនឈ្មោះបេក្ខជនមួយរូប ទៅគណៈកម្មាធិការនាយក ព.ស.ក ដើម្បីស្នើសុំតែង តាំង ជំនួស។

**ប្រការ ១៨**- គណៈកម្មាការ ព.ស.ក ខេត្ត ក្រុង មានសមាសភាព ដូចតទៅនេះ :

| | |
|---|---|
| -ប្រធាន | ១រូប |
| -អនុប្រធានអចិន្ត្រៃយ៍ | ១រូប |
| -សមាជិក | ៤រូប |
| -លេខាធិការ | ១រូប |
| -លេខាធិការរង | ១រូប |
| -ហេរញ្ញិក | ១រូប |

គណៈកម្មាការ ព.ស.ក ខេត្ត ក្រុង មានព្រះមេគណខេត្ត ក្រុង និង ឯកឧត្តមអភិបាលខេត្ត ក្រុង ជាប្រធានកិត្តិយស ឯកឧត្តមអភិបាលរងខេត្ត ក្រុង ជាសមាជិកកិត្តិយស ព្រះបាឡាត់គណ និងមន្ត្រីនៃមន្ទីរធម្មការខេត្ត ក្រុង ជាទីប្រឹក្សា ។

**លក្ខន្តិកៈពុទ្ធិកសមាគមកម្ពុជរដ្ឋ**

ប្រធានកិត្តិយស សមាជិកកិត្តិយស និងទីប្រឹក្សានៃ ព.ស.ក ខេត្ត ក្រុង មានសិទ្ធិផ្តល់មតិណែនាំដល់ ព.ស.ក ខេត្ត ក្រុង គ្រប់កាលៈទេសៈ ។

គណៈកម្មការ ព.ស.ក ខេត្ត ក្រុង អាចបង្កើតអនុគណៈកម្មការមួយចំនួនទៀតបានទៅតាមតម្រូវការរបស់ខ្លួន ។

ក្នុងករណីដែលពុទ្ធមាមកជនខ្មែរ នៅប្រទេសក្រៅណាមួយ បានស្ម័គ្រចិត្តចូលជាកម្មិកសមាជិក ព.ស.ក មានចំនួនពី ១០០នាក់ឡើងទៅ អាចបង្កើតគណៈកម្មការ ព.ស.ក ដោយឡែកបាន តាមប្រការ ១៨ នៃលក្ខន្តិកៈ និងការអនុវត្តន៍ភារកិច្ចរបស់គណៈកម្មការនោះ ដូចមានចែងក្នុងប្រការទាំងឡាយ សម្រាប់គណៈកម្មការ ព.ស.ក ខេត្ត ក្រុង ។

**ប្រការ ១៩**- មហាសន្និបាត ព.ស.ក ខេត្ត ក្រុង ជ្រើសតាំងស្នងការគណនេយ្យ ៣រូប សម្រាប់អាណត្តិ ២ឆ្នាំ ។

## ជំពូក ៤

## មុខការ

**ប្រការ ២០**- មុខការទាំងឡាយរបស់សមាជិក នៃគណៈកម្មាធិការនាយក ព.ស.ក គណៈកម្មការ ព.ស.ក ខេត្ត ក្រុង ព្រមទាំងប្រធាន និង សមាជិកនៃគណៈកម្មការ និងអនុគណៈកម្មការផ្សេងៗទៀត ជាមុខការដែលត្រូវបំពេញដោយស្ម័គ្រចិត្ត (ដោយគ្មានកម្រៃ)។ ប៉ុន្តែសមាជិកទាំងនោះ ត្រូវបានទទួលការឧបត្ថម្ភពី គណៈកម្មាធិការនាយក ព.ស.ក ឬគណៈកម្មការ ព.ស.ក ខេត្ត ក្រុង នូវមធ្យោបាយ និងថវិកាសមស្រប សម្រាប់ការចំណាយក្នុងការបំពេញបេសកកម្មជាប្រយោជន៍របស់ ព.ស.ក ។

**ប្រការ ២១**- ប្រធានគណៈកម្មាធិការនាយក ជាអ្នកអនុវត្តនិងតាមដានការអនុវត្តលក្ខន្តិកៈ ព.ស.ក និងសេចក្តីសម្រេចនានា របស់គណៈកម្មាធិការនាយក ព.ស.ក និងរបស់មហាសន្និបាត ព្រមទាំងទទួលបន្ទុកភារកិច្ចស្នូលទាំងឡាយ ដូចតទៅ:

-ចុះហត្ថលេខាលើលិខិតស្នាម ទាំងអស់ដែលទាក់ទិនទៅនឹង ព.ស.ក ។

-ជាអ្នកតំណាងផលប្រយោជន៍គ្រប់យ៉ាងរបស់ ព.ស.ក ចំពោះរដ្ឋ និងចំពោះជនានុជន ។

-ជាអ្នកទទួលខុសត្រូវចំពោះប្រាក់ចំណូល ចំណាយទូទៅ នៅក្នុងអាណត្តិរបស់ខ្លួន ។

-សម្រេចលើការចំណាយ ដែលមិនលើសពី ១.០០០.០០០៛០០ (មួយលានរៀល ) ករណីមានចំណាយលើសពីនេះ ត្រូវមានការឯកភាពពីគណៈកម្មាធិការនាយក ព.ស.ក ។

-ជាអ្នកទទួលខុសត្រូវក្នុងការចំណាយ ដែលគ្មានអ្វីជាឯកសារសំអាង ។

នៅពេលប្រធានអវត្តមាន អនុប្រធានទី១ ត្រូវទទួលបន្ទុកជាប្រធានស្តីទី ហើយនៅពេលប្រធាន និងអនុប្រធានទី១ អវត្តមាន អនុប្រធានទី២ ត្រូវទទួលបន្ទុកជាប្រធានស្តីទី ។

នៅពេលអគ្គលេខាធិការអវត្តមាន អនុប្រធានទី១ ត្រូវទទួលបន្ទុកបន្ថែមនូវភារកិច្ចអគ្គលេខាធិការ ។

**លក្ខន្តិកៈពុទ្ធិកសមាគមកម្ពុជរដ្ឋ**

នៅពេលហេរញ្ញិកអវត្តមាន គណនេយ្យករ ត្រូវទទួលបន្ទុកភារកិច្ចជំនួស ។

**ប្រការ ២២**- អគ្គលេខាធិការ ជាអ្នកសម្រុះសម្រួលកិច្ចការរបស់គណៈកម្មការទាំងឡាយ និងទទួលខុសត្រូវចំពោះឯកសារកិច្ចការរដ្ឋបាល ហិរញ្ញកិច្ច ព្រមទាំងលិខិតស្នាមផ្សេងៗ របស់ ព.ស.ក ។

ប្រការ ២៣- ហេរញ្ញិកមានមុខការ ដូចតទៅ :

-ទារប្រាក់ភាគទាន ។

-ទទួលប្រាក់ និង ទេយ្យវត្ថុផ្សេងៗ ដែលសប្បុរសជនធ្វើអំណោយ ដល់ ព.ស.ក ។

-ចេញប្រាក់ចំណាយ ដែលគណៈកម្មាធិការនាយក ព.ស.ក បានសម្រេចឱ្យចាយ ។

-ទទួលខុសត្រូវលើបញ្ជីគណនេយ្យ និងប្រាក់ក្នុងហិប របស់ ព.ស.ក ដែលខ្លួនកាន់កាប់ ។

-ធ្វើសេចក្ដីរាយការណ៍ជាលាយលក្សណ៍អក្សរ អំពីប្រាក់ចំណូល ចំណាយប្រចាំខែ គ្រប់ពេលប្រជុំ ពេលមហាសន្និបាត ឬពេលណាដែលប្រធានចង់ដឹង ។

**ប្រការ ២៤**- ហេរញ្ញិក មិនអាចទុកប្រាក់ក្នុងហិបរបស់ ព.ស.ក លើសពី ១.២០០.០០០៛០០ ( មួយលានពីរសែនរៀល) ឡើយ។ ប្រាក់ដែលលើសពីចំនួននេះ ត្រូវយកទៅដាក់ផ្ញើ ក្នុងនាម និង សម្រាប់គណនីរបស់ ព.ស.ក នៅធនាគារណាមួយ ដែលគណៈកម្មាធិការនាយកចាត់តាំង។

ហេរញ្ញិកនឹងដកប្រាក់ពីធនាគារបាន លុះណាតែមានហត្ថលេខាពីរ (២) នាក់ គឺប្រធានគណៈកម្មាធិការនាយក និងហេរញ្ញិក ។

**ប្រការ ២៥**- អនុប្រធាន ជាអ្នកជួយធ្វើការប្រធាន ។

-លេខាធិការ ជាអ្នកជួយធ្វើការអគ្គលេខាធិការ ។

-គណនេយ្យករ ជាអ្នកជួយធ្វើការហេរញ្ញិក ។

-បេឡាធិការ ជាអ្នកបំពេញភារកិច្ចដែលហេរញ្ញិកប្រគល់ឱ្យ ។

**ប្រការ ២៦**- សមាជិករបស់គណៈកម្មាធិការនាយក ព.ស.ក ឬសមាជិកគណៈកម្មការ ព.ស.ក ខេត្ត ក្រុង បំពេញបេសកកម្មគ្រប់យ៉ាង ដែលគណៈកម្មាធិការនាយក ឬគណៈកម្មការខេត្ត ក្រុង ចាត់តាំង។

**ប្រការ ២៧**- ប្រធានគណៈកម្មការ ព.ស.ក ខេត្ត ក្រុង ទទួលបន្ទុក ភារកិច្ច ដូចតទៅ :

-អនុវត្តតាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការនាយក ព.ស.ក និង ចុះហត្ថលេខាក្នុងនាមគណៈកម្មការ ព.ស.ក របស់ខ្លួន លើលិខិតទាំងឡាយដែលទាក់ទងនឹង ព.ស.ក ។

-ទទួលខុសត្រូវលើប្រាក់ចំណូលចំណាយរបស់គណៈកម្មការ ព.ស.ក ខេត្ត ក្រុង ចំពោះមុខគណៈកម្មាធិការនាយក ព.ស.ក និង ចំពោះមុខច្បាប់ ។

-មិនត្រូវចំណាយប្រាក់ជាប្រយោជន៍ ព.ស.ក ឱ្យហួសពី ៥០០.០០០៛០០ ( ប្រាំសែនរៀល ) ទេ ។ បើមានការចំណាយលើសពីនេះ ត្រូវមានសេចក្ដីយល់ព្រមពី គណៈកម្មការ ព.ស.ក របស់ខ្លួនជាមុនសិន។

ប្រការ ២៨- អនុប្រធានអចិន្ត្រៃយ៍ និង លេខាធិការ ព.ស.ក ខេត្ត ក្រុង ជាអ្នកជួយធ្វើការប្រធាន ។

**លក្ខន្តិកៈពុទ្ធិកសមាគមកម្ពុជរដ្ឋ**

**ប្រការ ២៩**- ហេរញ្ញិកនៃគណៈកម្មការ ព.ស.ក ខេត្ត ក្រុង មានមុខការ ដូចតទៅនេះ :

-ទារប្រាក់ភាគទាន ។

-ទទួលប្រាក់ និងទេយ្យវត្ថុផ្សេងៗ ដែលសប្បុរសជនធ្វើអំណោយដល់ ព.ស.ក ។

-ទូទាត់ប្រាក់ចំណាយ ដែលគណៈកម្មការ ព.ស.ក បានសម្រេច ។

-កាន់បញ្ជីគណនេយ្យរបស់ ព.ស.ក ហើយត្រូវរាយការណ៍ពីប្រាក់ចំណូល ចំណាយ ជូនប្រធានគណៈកម្មការ ព.ស.ក ខេត្ត ក្រុង ជាទៀងរាល់ខែ និងនៅពេលណាដែលប្រធានចង់ដឹង ។

-មិនអាចទុកប្រាក់ក្នុងហិបរបស់គណៈកម្មការ ព.ស.ក ខេត្ត ក្រុង ឱ្យលើសពី ៧០០.០០០រ០០ (ចិតសិបម៉ឺនរៀល) ទេ។ ប្រាក់ដែលលើសពីនេះ ត្រូវផ្ញើទុកនៅធនាគារណាមួយ។

**ប្រការ ៣០**- គណៈកម្មការ ព.ស.ក ខេត្ត ក្រុង ត្រូវបង់ប្រាក់ចំនួន មួយភាគបី (១/៣) នៃប្រាក់ចំណូល ទាំងអស់របស់ខ្លួន ទៅគណៈកម្មាធិការនាយក ព.ស.ក ជាទៀងរាល់ត្រីមាស។ គណៈកម្មការ ព.ស.ក ខេត្ត ក្រុង អាចធ្វើ អំណោយប្រាក់ដល់គណៈកម្មាធិការនាយក ព.ស.ក ដើម្បីមានលទ្ធភាពបំពេញភារកិច្ចធំៗ បាន។

## ជំពូក៥

## ធនធាន

**ប្រការ ៣១**- ធនធានរបស់ ព.ស.ក បានមកពី :

ក- ប្រាក់ភាគទានរបស់សមាជិកគ្រប់ប្រភេទ

ខ- ប្រាក់វិភាគទានអំពីប្រភពផ្សេងៗ

គ- ប្រតិលាភផ្សេងៗ

ឃ- សង្ហារឹម អសង្ហារឹម ដែលមានក្នុង ព.ស.ក ។

## ជំពូក ៦

## មហាសន្និបាត

**ប្រការ ៣២**- សមាជិកទាំងឡាយនៃគណៈកម្មការ ព.ស.ក ខេត្ត ក្រុង និង តំណាងគណៈកម្មការ ព.ស.ក នៅក្រៅប្រទេស ជាប្រតិភូនៃសមាជិកក្នុងតំបន់របស់ខ្លួនចូលរួមក្នុងមហាសន្និបាត ។

**ប្រការ ៣៣**- រៀងរាល់ពីរឆ្នាំម្តង នៅអំឡុងខែមីនា ឬខែមេសា តាមសេចក្តីអញ្ជើញរបស់ប្រធាននៃគណៈកម្មាធិការនាយក ព.ស.ក ប្រតិភូទាំងឡាយនៃ ព.ស.ក ខេត្ត ក្រុង និង ក្រៅប្រទេស ទៅរួមប្រជុំនៅទីក្រុងភ្នំពេញជាមហាសន្និបាតសាមញ្ញ ដើម្បី:

ក-ស្តាប់សេចក្តីរាយការណ៍ប្រចាំអាណត្តិ របស់គណៈកម្មាធិការនាយក ព.ស.ក អំពីបញ្ហា ទាំងឡាយ ដែលទាក់ទងនឹហ ព.ស.ក និង សេចក្តីរាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ និងខាងផ្លូវចិត្ត ប្រចាំអាណត្តិ។

ខ- ជ្រើសតាំងគណៈកម្មការបោះឆ្នោត ៥រូប សម្រាប់ដំណើការជ្រើសរើសសមាសភាព គណៈកម្មាធិការនាយក ព.ស.ក ប្រចាំអាណត្តិថ្មី ។

គ- ដំណើរការបោះឆ្នោតជ្រើសរើសសមាសភាពគណៈកម្មាធិការនាយក ព.ស.ក ប្រចាំអាណត្តិថ្មី ។

ឃ- ពិភាក្សា អនុម័តវិសោធនកម្មលក្ខន្តិកៈព.ស.ក និងពិភាក្សាអនុម័តបញ្ហានានា របស់មហាសន្និបាត។

**ប្រការ ៣៤**- ប្រធានគណៈកម្មាធិការនាយក ព.ស.ក ធ្វើសេចក្តីអញ្ជើញ ដោយផ្សាយតាមកាសែត វិទ្យុ ទូរទស្សន៍ និងតាមសំបុត្រក្នុងរយៈពេល២០ ថ្ងៃ យ៉ាងតិច មុនកាលបរិច្ឆេទនៃការប្រជុំ ។

**ប្រការ ៣៥**- សមាសភាពនៃគណៈកម្មការបោះឆ្នោត ត្រូវមានប្រធានមួយរូប លេខាធិការ១រូប និងសមាជិក ៣ រូប ។

**ប្រការ ៣៦**- បើមានការប្រញាប់ ឬដោយមានពាក្យស្នើសុំ មានចុះហត្ថលេខា មួយភាគបួន (១/៤ ) នៃចំនួន គណៈកម្មការ ព.ស.ក ខេត្ត ក្រុងទាំងអស់ ឬពីភាគបី (២/៣ ) នៃសមាជិកគណៈកម្មាធិការនាយក ព.ស.ក ប្រធានអាចអញ្ជើញសមាជិក ធ្វើមហាសន្និបាតវិសាមញ្ញបាន ។

**ប្រការ ៣៧**- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ នឹងពិភាក្សាទៅទុកជាបានការ លុះត្រាណាតែសមាជិកដែល បានមកប្រជុំ មានចំនួនយ៉ាងតិច មួយភាគប្រាំ (១/៥) នៃចំនួនប្រតិភូរបស់ខេត្ត ក្រុង ដែលមានសំបុត្រអញ្ជើញ ប្រមទាំងមួយភាគប្រាំ (១/៥ ) នៃចំនួនសមាជិកនៅក្រុងភ្នំពេញ ដែលគណៈកម្មាធិការនាយក ព.ស.ក បាន អញ្ជើញ ។

**ប្រការ ៣៨**- កាលបើមានមហាសន្និបាត មិនអាចពិភាក្សាបាន ដោយខ្វះសមាជិកគ្រប់ចំនួន (កូរ៉ុម ) នោះត្រូវធ្វើសេចក្តីអញ្ជើញជាថ្មី ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយមក ។

មហាសន្និបាត ដែលប្រជុំដោយសេចក្តីអញ្ជើញលើកទី ២ អាជពិភាក្សា ទៅទុកថាជាបានការ តាមតែ ចំនួនសមាជិកមកប្រជុំប៉ុន្មានក៏ដោយ ។

**ប្រការ ៣៩**- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកតាមមតិភាគច្រើន ដាច់ខាត (ឆ្នោត ៥០% +១)។ បើសម្លេងឆ្នោតមានចំនួនស្មើគ្នា (៥០% ដូចគ្នា ) នោះត្រូវបោះសារជាថ្មី ។ ប៉ុន្តែ បើសម្លេងឆ្នោតនៅតែស្មើគ្នា ទៀត នោះសម្លេងប្រធាន (ប្រធានគណៈកម្មការបោះឆ្នោត ឬ ប្រធានគណៈកម្មាធិការនាយក ) មាន ឧត្តមានុភាព ។

**ប្រការ ៤០**- នៅរាល់ការប្រជុំមហាសន្និបាត ដើម្បីជ្រើសតាំង គណៈកម្មាធិការនាយក ព.ស.ក ថ្មី ត្រូវធ្វើសេចក្តីកត់ហេតុមួយ ដែលមានចុះហត្ថលេខារបស់ប្រធាន និងលេខាធិការនៃគណៈកម្មការបោះឆ្នោត ។

រាល់ការប្រជុំក្រៅពីនេះ ត្រូវធ្វើសេចក្តីកត់ហេតុមួយដោយមានចុះហត្ថលេខា របស់ប្រធានអង្គប្រជុំ និង លេខាធិការអង្គប្រជុំ ។

**ប្រការ ៤១**- ការប្រជុំពិភាក្សា របស់គណៈកម្មាធិការនាយក ព.ស.ក និងគណៈកម្មការ ព.ស.ក ខេត្ត ក្រុង ដែលដំណើរការបាន លុះណាតែមានសមាជិក ដែលបានមកប្រជុំ មានចំនួនយ៉ាងតិច ពាក់កណ្តាលលើសមួយ (៥០% +១)នៃចំនួនសមាជិកទាំងអស់ ។

## ជំពូក៧

## ការរំលាយសមាគម

**ប្រការ ៤២**- វៀរលែងតែក្នុងករណីប្រធានស័ក្តិ មានតែមហាសន្និបាត ដែលមានសមាជិក ព.ស.ក តំណាងខេត្ត ក្រុងទាំងអស់ ត្រូវបានអញ្ជើញមកប្រជុំ ចំពោះតែរឿងរំលាយនេះ ហើយដែលមានឆ្នោត ពីរភាគបី (២/៣ ) នៃ ចំនួនសមាជិកដែលមកប្រជុំ យល់ប្រមផងប៉ុណ្ណោះទេ ទើបអាចរំលាយ ព.ស.ក បាន។

**ប្រការ ៤៣**- ប្រសិនបើមានការរំលាយ ថវិកាទាំងអស់ រួមទាំងសង្ហារឹម និងអសង្ហារឹមទាំងឡាយ របស់ ព.ស.ក ត្រូវមហាសន្និបាតសម្រេច ដោយយកតាមមតិភាគច្រើន ដាច់ខាត (៥០% +១) នៃសមាជិកមក រួមប្រជុំ ។

## បទបញ្ញត្តិផ្សេងៗ

**ប្រការ ៤៤**- លើកលែងតែប្រធានកិត្តិយស និង សមាជិកកិត្តិយស សមាជិក ព.ស.ក ទាំងអស់ ត្រូវប្រតិបត្តិតាម លក្ខន្តិកៈ ព.ស.ក ។

**ប្រការ ៤៥**- មានតែភាគច្រើនដាច់ខាត (៥០% +១) នៃសមាជិកមហាសន្និបាតប៉ុណ្ណោះទេ ដែលអាចកែប្រែ បញ្ញត្តិទាំងឡាយ នៃលក្ខន្តិកៈនេះបាន។

សមាជិកណាម្នាក់ យល់ឃើញថា គួរកែប្រែ ឬកែលំអប្រការណាមួយ ក្នុងលក្ខន្តិកៈរបស់ ព.ស.ក សមាជិកនោះត្រូវធ្វើសេចក្តី សុំកែប្រែ ឬកែលំអជាលាយលក្សណ៍អក្សរ ដោយសមាជិក ព.ស.ក ៣នាក់គាំទ្រ និងដោយមានការឯកភាព ពីគណៈកម្មការ ព.ស.ក ខេត្ត ក្រុងផង ហើយផ្ញើជូនទៅគណៈកម្មាធិការនាយក ព.ស.ក ឱ្យបានមួយខែយ៉ាងតិច មុនធ្វើមហាសន្និបាត ។

**ប្រការ ៤៦**- បើមហាសន្និបាតយល់ឃើញថា ត្រូវកែប្រែ ឬកែលំអ ប្រការណាមួយក្នុងលក្ខន្តិកៈរបស់ ព.ស.ក នោះត្រូវមានការបោះឆ្នោត លើសេចក្តីស្នើនោះ ដោយមានសន្លឹកឆ្នោតគាំទ្រ ពីរភាគបី (២/៣) នៃសម្លេងក្នុង មហាសន្និបាត ទើបអាចសម្រេចបាន ។

**លក្ខន្តិកៈពុទ្ធិកសមាគមកម្ពុជរដ្ឋ**

**ប្រការ ៤៧**- ការចាត់តាំងអ្នកតំណាង ព.ស.ក ឱ្យទៅបំពេញបេសកកម្ម ទស្សនកិច្ចសិក្សា នៅក្នុងប្រទេស ឬនៅក្រៅប្រទេស គឺជាមុខការរបស់គណៈកម្មាធិការនាយក ព.ស.ក ដែលសម្រេចតាម ពីរភាគបី (២/៣ ) នៃចំនួនសមាជិក គណៈកម្មាធិការនាយក ។

ភ្នំពេញ . ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០១

គណៈកម្មាធិការនាយក

**ប្រធាន**

**ចាន់ វ៉ែន**